# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីមាតាបិតាសង្គ្រោះកូនប្រុសស្រីដោយធម៌៥យ៉ាង

web site: hoksavann.org

ថ្ងៃទី២៩ កក្កដា ២០០៥

ព្រះពុទ្ធសាសនាសំដែងថា មាតាបិតាក្រៅពីការចិញ្ចឹមកូនឲ្យរស់រានមានជីវិតហើយ ត្រូវមានភារកិច្ចសង្គ្រោះកូនដោយធម៌៥យ៉ាងទៀតគឺ ៖

១- បាបានិវារេន្តិ ប្រែថាហាមឃាត់កូនធ្វើអំពើបាប ។ មានន័យសេចក្ដីថា មាតាបិតាជាបុព្វចារ្យ ប្រែថាជាគ្រូខាងដើមមុនក្នុងសាលារបស់រដ្ឋ កូនប្រុសស្រីនៅក្នុងបឋមវ័យពុំទាន់ដឹងខុសត្រូវ បុណ្យបាបគុណទោសអ្វីឡើយ ដូច្នេះមាតាបិតាមានភារៈនិងមុខនាទីជាចាំបាច់ មិនត្រឹមតែបង្រៀនកូនឲ្យចេះនិយាយស្ដីប៉ុណ្ណោះទេ តែត្រូវបង្រៀនឲ្យចេះនិយាយស្ដីត្រឹមត្រូវ និងបង្រៀនឲ្យជៀសវាងអំពើអាក្រក់គ្រប់យ៉ាង ដែលជាអំពើនាំឲ្យគ្រួសារ ក៏ដូចជាប្រទេសជាតិចុះខ្សោយខាងសីលធម៌ ។

២- កល្យាណេ និវេសេន្តិ ប្រែថា ឲ្យកូនតាំងនៅក្នុងសេចក្ដីល្អ ។ មានន័យថា មាតាបិតា ក្រៅពីការហាមឃាត់កូនកុំឲ្យប្រព្រឹត្តធ្វើអំពើអាក្រក់ ត្រូវបង្ហាត់បង្រៀនឲ្យប្រព្រឹត្តធ្វើអំពើល្អ ។ ក្នុងន័យនេះបញ្ជាក់ថា មាតាបិតាមិនត្រឹមតែចិញ្ចឹមកូនឲ្យរស់ប៉ុណ្ណោះទេ តែត្រូវពន្យល់បង្ហាញកូនឲ្យស្គាល់មាគ៌ាជីវិត របៀបរស់នៅក្នុងសង្គម ដើម្បីឲ្យកូនយល់ច្បាស់ ព្រោះថាកូននឹងត្រូវគ្រប់គ្រងជីវិតដោយខ្លួនឯងនាអនាគត នៅពេលដែលបែកចេញពីមាតាបិតាទៅ ។ ការអប់រំនេះជាធាតុសំខាន់ណាស់ បើមាតាបិតាមានវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិខ្ពស់ ការអប់រំកូនក៏មានកំរិតខ្ពស់ដែរ ។

៣- ករិប្បំ សិក្ខាបេន្តិ ប្រែថា ឲ្យកូនសិក្សានូវវិជ្ជាផ្សេងៗ ។ មានន័យថា មាតាបិតាបានអប់រំកូន ទុកជាការត្រួសត្រាយផ្លូវឲ្យបានយល់អំពីមាគ៌ាជីវិតបានមួយភាគហើយ តមកទៀតត្រូវបញ្ជូនកូនឲ្យទៅសិក្សានូវចំណេះវិជ្ជាផ្សេងៗ នៅក្នុងសាលារដ្ឋ ចាប់ពីបឋមវ័យទៅ ដើម្បីឲ្យកូនមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ទោះបីទៅធ្វើការបំរើរដ្ឋក្ដី ទៅប្រកបការងារណាមួយក្ដី នឹងបានជោគជ័យក្នុងវិជ្ជាជីវៈព្រោះមានសមត្ថភាពគ្រប់គ្រាន់ ។

៤- បដិរូបេន ទារេន សំយោជេន្តិ ប្រែថាត្រូវរៀបចំកូនឲ្យមានស្វាមីភរិយាដ៏សមគួរដល់ឋានៈរបស់ខ្លួន ។ ប្រពៃណីខ្មែរ ការរើសគូស្រករ ក៏បន្ទុកស្ថិតនៅលើមាតាបិតា ជាមួយនិងការព្រមព្រៀង ឬមិនព្រមព្រៀងរបស់កូនផង ។ ពាក្យថាមិនសមគួរបានសេចក្ដីថា ត្រូវពិនិត្យមើលចរិយាមារយាទ ចំណេះដឹង ទ្រព្យសម្បត្តិ យសសក្ដិរបស់កូនប្រសារឲ្យត្រូវគ្នា ឬកុំឲ្យខុសឆ្ងាយពេកពីកូនខ្លួន ព្រោះកុំឲ្យមានការពិបាកនៅពេលក្រោយ ដោយសារការប្រកាន់ឋានៈគ្នា ។ មាតាបិតាបំពេញក្នុងធម៌ទី៤នេះ ចំពោះតែកូនប្រុសស្រីដែលគេចង់បានស្វាមីភរិយាប៉ុណ្ណោះ ។ បើកូនមិនចង់បានទេ ដូចជាកូនប្រុសចង់ទៅបួស ហើយចង់រស់នៅក្នុងភេទជាអ្នកបួសរហូត ឯកូនស្រីចង់នៅលីវរហូត ចង់រក្សាសីលធ្វើជាដូនជី ជាសីលវតី ដោយមានការនឿយណាយក្នុងជីវភាពមានគូស្រករ នោះមាតាបិតាត្រូវតែធ្វើតាមបំណងរបស់កូន ដោយមិនត្រូវបង្ខំកូនឲ្យមានគូស្រករឡើយ ។

៥- សមយេ ទាយជ្ជំ និយ្យាទេន្តិ ប្រែថា ចែកទ្រព្យសម្បត្តិដល់កូនក្នុងសម័យដ៏គួរ ។ មានន័យថា មាតាបិតាពុំមែនចិញ្ចឹមកូនរហូតទេ នៅពេលកូនធំពេញរូបរាង មានសមត្ថភាពអាចធ្វើការរកស៊ីដោយខ្លួនឯងបានហើយ ត្រូវផ្ដល់ដើមទុនឲ្យកូនរកស៊ី ។ ពាក្យខ្មែរថា កូនមានស្លាបហើរបានហើយ មាតាបិតាគ្រាន់តែជូនដំណើរ កវែកកន្ត្រាំងឲ្យកូនប៉ុណ្ណោះ កូនត្រូវបន្តដំណើរជីវិតដោយខ្លួនឯងតទៅទៀត ។ មត៌កដ៏សំខាន់ដែលមាតាបិតាចែកឲ្យកូនគឺចំណេះវិជ្ជា ដែលមាតាបិតាត្រូវតែជំរុញឲ្យកូនសិក្សារៀនសូត្រឲ្យបានកំរិតខ្ពស់ ព្រោះនេះជាកិត្តិយសគ្រួសារនិងជាអនាគតយុវជននិងយុវនារីដ៏ល្អរបស់ជាតិ ។

ក្នុងន័យនេះ ក្រសួងអប់រំមានភារកិច្ចចាំបាច់ណាស់ ក្នុងការធ្វើកម្មវិធីសិក្សាបណ្ដុះស្មារតីជាតិដល់យុវជននិងយុវនារីខ្មែរទាំងនោះ ដោយតម្រូវឲ្យសិក្សានូវមុខវិជ្ជាចាំបាច់ ដូចជាពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា និងចរិយាវិជ្ជាជាដើម ។៚